**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គជអប
NCDD

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប**
**ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥

# សេចក្តីប្រកាសព័ត៌មាន
# សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សូមជូនដំណឹងដល់បណ្ដាញសារព័ត៌មានទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា លេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំសិក្ខាសាលាជាតិ ស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ នៃការអនុវត្តផអ៣ ដំណាក់កាលទី២ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលប្រព្រឹត្តទៅក្នុងពិធីបើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាអនុប្រធាន គ.ជ.អ.ប** និងក្នុងពិធីបិទ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយក រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**។

សិក្ខាសាលាថ្នាក់ជាតិនេះ មានគោលបំណងពិភាក្សាអំពីការវិភាជន៍ថវិកា និងលទ្ធផលរំពឹងទុកសម្រាប់ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ និងវឌ្ឍនភាព បញ្ហាប្រឈមនានាក្នុងឆ្នាំ២០១៥។

សិក្ខាសាលានឹងមានការចូលរួមពីតំណាងក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលជាសមាជិក គ.ជ.អ.ប តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងក្រសួង ស្ថាប័នអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ប្រធានក្រុមប្រឹក្សា អភិបាលរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានាសរុបប្រមាណជា៥០៧ រូប។

គោលបំណងចម្បងនៃផអ៣ទី២ គឺជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានបានកាន់តែច្រើន កាន់តែល្អប្រសើរ កាន់តែមានលក្ខណៈឆ្លើយតបចំពោះសេចក្តីត្រូវការរបស់

ប្រជាពលរដ្ឋរបស់ខ្លួន។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ផអព៣ទី២ ផ្តោតលើទិដ្ឋភាពសំខាន់ៗដូចជា៖ ការធ្វើវិមជ្ឈការមុខងារផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានចាំបាច់នានា ការបង្កើនធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងនោះដែលរ ផអព៣ទី២ មានសមិទ្ធផលធំៗចំនួន៥គឺ ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងវមជ្ឈការហិរញ្ញវត្ថុ។

**ទីកន្លែង៖** សណ្ឋាគារសុខា ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

**ពេលវេលា៖** ថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០១៥ ចាប់ពីម៉ោង ៧:០០ព្រឹក ដល់ម៉ោង ០៥:០០ ល្ងាច

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីដែលជាអ្នកសារព័ត៌មាន ចូលរួមយកព័ត៌មានកុំបីខាន។


*ព័ត៌មានបន្ថែម សូមទំនាក់ទំនងលេខាធិការដ្ឋាន គ.ជ.អ.ប*

*លេខទូរស័ព្ទ ០៧៨ ៥៧៥ ៧៧៥/០៨៨ ៧៥៧ ៥៥៧*

*E-mail: tharith@ncdd.gov.kh*

*Website: www.ncdd.gov.kh*